**នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ

ភាគីដាក់ឯកសារ: មេធាវីការពារក្តីរបស់លោកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈដោយមានឧបសម្ព័ន្ធ ក ជាឯកសារសម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សាធារណៈ/Public**

ប្រភេទចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 28-Jul-2011, 10:54
CMS/CFO: Ly Bunloung

---

**ចម្លើយតបរបស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ទៅនឹង "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះអង្គជំនុំជម្រះសាលាដំបូង"**

---

**<u>មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ៖</u>**

លោក ផាត់ ពៅស៊ាង

លោក Diana ELLIS, QC

**<u>ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖</u>**

ចៅក្រម និល ណុន ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូ អុតារ៉ា

ចៅក្រម Jean-Marc LA VERGNE

ចៅក្រម យ៉ា សុខន

**<u>សហព្រះរាជអាជ្ញា៖</u>**

លោកស្រី ជា លាង

លោក Andrew CAYLEY

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ពេជ អង្គ

Elisabeth SIMONNEAU FORT

## I. **សេចក្ដីផ្ដើម**

១. នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់ "សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" (**សំណើរបស់ ក.ស.ព**)[១] ដោយស្នើសុំអង្គជំនុំជម្រះសាលាដំបូង (ក)ប្រកាសថាគ្មានសិទ្ធិដាច់ខាតក្នុងការកោះហៅសាក្សីទាំងអស់ដែលចម្លើយរបស់ពួកគេកំពុងត្រូវបានស្នើឲ្យបញ្ចូលជាភស្តុតាង, (ខ)សម្រេចលើភាពចាំបាច់សម្រាប់សាក្សីបង្ហាញខ្លួន នៅពេលសវនាការសួរដេញដោល នៅពេលចាប់ផ្ដើមដំណាក់កាលពាក់ព័ន្ធនានានៃកិច្ចដំណើរការនីតិវិធី និង (គ) យកគោលការណ៍ណែនាំទូទៅនៃវិធាន៩២*ស្ដូច* និងយុត្តិសាស្ត្ររបស់ ICTY[២]។ នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១១ មេធាវីការពារក្ដីបានទទួលព័ត៌មានពីអង្គជំនុំជម្រះសាលាដំបូងថា កាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់ចម្លើយតបទៅនឹងសំណើរបស់ ក.ស.ព ត្រូវបានពន្យាររហូតដល់ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១[៣]។ ដូចនេះ មេធាវីការពារក្ដីសូមដាក់ចម្លើយតបទៅនឹងសំណើរបស់ ក.ស.ព ដូចខាងក្រោម។

២. វិធាន៨៤(១) នៃវិធានផ្ទៃក្នុងផ្ដល់ឲ្យជនជាប់ចោទនូវសិទ្ធិតាមផ្លូវច្បាប់ក្នុងការសួរដេញដោលយ៉ាងហោចណាស់ចំពោះសាក្សីដែលផ្ដល់ភស្តុតាងដាក់បន្ទុកជនជាប់ចោទក្នុងកិច្ចដំណើរការនីតិវិធីខាងមុខដែរ។ ជាងនេះទៀត កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ដែលបានដាក់នៅក្នុងសំណុំរឿង មិនមែនជាតំណាងត្រឹមត្រូវ និងគួរឲ្យទុកចិត្តនៃខ្លឹមសារនៃចម្លើយសាក្សី និងមិនគួរសម្រេចទទួលយកធ្វើជាភស្តុតាងដោយគ្មានសក្ខីកម្មផ្ទាល់របស់សាក្សីឡើយ។ ភស្តុតាងទាំងអស់ដែលប្រើជាសំអាងដើម្បីគាំទ្រដល់ការផ្ដន្ទាទោសជនជាប់ចោទ គួរឆ្លងកាត់ការត្រួតពិនិត្យពីសំណាក់មេធាវីការពារក្ដីក្នុងនាមជនជាប់ចោទសិន។

---

[១] ក.ស.ព, សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារលេខ E96។ មេធាវីការពារក្ដីបានទទួលការជូនដំណឹងពីឯកសារនេះនៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

[២] សំណើរបស់ ក.ស.ព កថាខណ្ឌ៤១។

[៣] បានបញ្ជាក់នៅអង្គជំនុំជម្រះសាលាដំបូង, សេចក្ដីសម្រេចលើសំណើសុំពន្យារពេល ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារលេខ E107។

## II. បញ្ញត្តិច្បាប់

៣. ខាងក្រោមនេះគឺជាបញ្ញត្តិច្បាប់នានាដែលពាក់ព័ន្ធ ៖

**វិធាន ៨៤ : ការចូលខ្លួនរបស់សាក្សី និងអ្នកជំនាញ**

១. ជនជាប់ចោទមានសិទ្ធិស្នើសុំឱ្យកោះហៅសាក្សីដាក់បន្ទុកដែលជនជាប់ចោទមិនទាន់មានឱកាសតទល់នៅដំណាក់កាលមុនពេលជំនុំជម្រះ។

**មាត្រា ៣៥*ថ្មី* នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក**

ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។

នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា ស្របតាមមាត្រា១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ [...]

ង. ពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភស្តុតាងដោះបន្ទុក ក្នុងលក្ខខណ្ឌដូចគ្នានឹងភស្តុតាងដាក់បន្ទុកដែរ [...]។

**មាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា**

១. សិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងមាត្រា១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិ ឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី។ សិទ្ធិបែបនេះជាពិសេសរួមមានសិទ្ធិទទួលបានសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថាគ្មានទោសពៃរ៍ហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង សិទ្ធិមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំពេលវេលាការពារខ្លួន សិទ្ធិទទួលបាននូវមេធាវី ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និងសិទ្ធិពិនិត្យ ឬបានពិនិត្យសាក្សីដាក់បន្ទុក។

២. អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា ប្រការស្តីពីសិទ្ធិទទួលបានមេធាវីការពារក្តីក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញចែងថា ជន

ជាប់ចោទមានសិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯងដូចដែលបានធានានៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

**មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)[៤]**

១. ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំនុំជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថភាព ឯករាជ្យ និងមិនលម្អៀងដែលបង្កើតឡើងដោយច្បាប់ជំនុំជម្រះរឿងក្តី របស់ខ្លួនដោយសមធម៌ និងជាសាធារណៈដើម្បីសម្រេចលើការចោទប្រកាន់មកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីកិច្ចក្នុងវិស័យព្រហ្មទណ្ឌ [...]។

៣. ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញដូចខាងក្រោម ៖

(ង) ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក [...]។

**មាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា**

សាក្សីខាងដាក់បន្ទុកដែលមិនទាន់បានសួរចម្លើយតទល់គ្នាជាមួយជនជាប់ចោទត្រូវតែកោះហៅឱ្យចូលរួមក្នុងសវនាការ។

## III. សេចក្តីសន្និដ្ឋានផ្នែកច្បាប់

### ៣.១ សិទ្ធិក្នុងការសួរដេញដោលសាក្សីដាក់បន្ទុកជនជាប់ចោទ

៤. ដូចមានបញ្ជាក់នៅក្នុងចំណងជើងនេះស្រាប់ វិធាន៨៤ នៃវិធានផ្ទៃក្នុងចែងអំពី<u>ការចូលខ្លួន</u>របស់សាក្សីនៅពេលជំនុំជម្រះក្តី។ ពាក្យពេចន៍ក្នុងវិធាន៨៤(១) នៃសំណៅឯកសារទាំងបីភាសា មាន

---

[៤] សិទ្ធិដូចគ្នានេះមានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ៦(១)(ឃ)នៃអនុសញ្ញាសហគមន៍អឺរ៉ុបស្តីពីសិទ្ធិមនុស្ស។

ភាពខុសគ្នា ហើយច្បាស់ណាស់ថា ភាពខុសគ្នានេះបណ្ដាលមកពីកំហុសឆ្គងដោយអចេតនាក្នុងការបកប្រែភាសា។ ទោះជាយ៉ាងនេះក្ដី វិធាន៨៤(១) ក្នុងឯកសារទាំងបីភាសា មានខ្លឹមសារដូចគ្នាដែលផ្ដល់សិទ្ធិតាមផ្លូវច្បាប់ដល់ជនជាប់ចោទសួរដេញដោលសាក្សីដែលសាក្សីអាចចូលខ្លួនតាមការតម្រូវរបស់ជនជាប់ចោទ។ ខ្លឹមសារនេះអាចយល់បានយ៉ាងច្បាស់លាស់តាមរយៈពាក្យ “ត្រូវ” ដែលមាននៅក្នុងសំណៅទាំងបីភាសា។ ការិយាល័យសហព្រះរាជអាជ្ញាអះអាងដោយខុសថា ការប្រើប្រាស់គុណនាម “ដាច់ខាត” គឺការដក “សិទ្ធិ”របស់ជនជាប់ចោទ។ ការប្រើប្រាស់គុណនាម “ដាច់ខាត” គ្រាន់តែចង់សង្កត់ធ្ងន់លើសិទ្ធិរបស់ជនជាប់ចោទប៉ុណ្ណោះ។ ការប្រើប្រាស់ពាក្យនេះមិនបង្កឲ្យមានភាពស្រពិចស្រពិលឡើយ។ ពាក្យទាំងនេះគ្មានការសង្ស័យ និងគួររក្សាអត្ថន័យដើម និងច្បាស់លាស់របស់វា។ ប្រសិនបើអ្នកបង្កើតវិធានមានបំណងដាក់កំហិតសិទ្ធិក្នុងការស្នើសុំសាក្សីឲ្យចូលរួមនោះ ការកំហិតទាំងនោះត្រូវតែចែងឲ្យបានច្បាស់លាស់។ សំខាន់ជាងនេះទៀត “សិទ្ធិ” នេះអាចយកមកអនុវត្តតែចំពោះសាក្សីដែលជនជាប់ចោទគ្មានឱកាសសួរដេញដោលក្នុងដំណាក់កាលមុនសវនាការប៉ុណ្ណោះ។ វិធានផ្ទៃក្នុងជាភាសាអង់គ្លេស និងភាសាខ្មែរមានការបញ្ជាក់បន្ថែមទៀតថា សិទ្ធិនេះមានទំនាក់ទំនងនឹងសាក្សីផ្ដល់ភស្តុតាងដាក់បន្ទុកជនជាប់ចោទ។ នៅពេលអនុវត្តវិធាន៨៤(១)នៃវិធានផ្ទៃក្នុង សិទ្ធិរបស់ជនជាប់ចោទមិនគួរមានការបញ្ជាក់បន្ថែមអ្វីទៀតទេ។

៥. ការទទួលស្គាល់សិទ្ធិរបស់ជនជាប់ចោទក្នុងសួរដេញដោលសាក្សី ដូចមានចែងក្នុងវិធាន ៨៤(១)នៃវិធានផ្ទៃក្នុង គឺគាំទ្រដល់សិទ្ធិដែលមានចែងក្នុងលិខិតុបករណ៍សិទ្ធិមនុស្សមួយចំនួន[៥] ដូចមានរៀបរាប់ខាងលើស្រាប់។ ជាពិសេស វិធាន ៨៤(១) ចែងដូចគ្នាទៅនឹងមាត្រា ២៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាដែលចែងថា សាក្សីដាក់បន្ទុកដែលមិនទាន់បានតទល់គ្នាជាមួយនឹងជនជាប់ចោទ ត្រូវតែកោះហៅ។

៦. ការិយាល័យសហព្រះរាជអាជ្ញាអះអាងដោយខុសថា អង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិក្នុងការទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី។ ការអះអាងដូចនេះពុំមានចែងនៅក្នុងវិធាន ៨៤ ឡើយ។ ប្រសិនបើលក្ខខណ្ឌចាំបាច់ដែលបានចែងក្នុងវិធាន ៨៤(១) ត្រូវបានបំពេញនោះ អង្គជំនុំជម្រះសាលាដំបូងពុំមានឆន្ទានុសិទ្ធិបដិសេធសិទ្ធិរបស់ជនជាប់ចោទក្នុងការទាមទារឲ្យមាន

---

[៥] មាត្រា ៣៥*ថ្មី* នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា ១៣ និង ១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (**ICCPR**), មាត្រា ៦ នៃអនុសញ្ញាសហគមន៍អឺរ៉ុបស្ដីពីសិទ្ធិមនុស្ស (**ECHR**)។

ការចូលរួមរបស់សាក្សីឡើយ។ ហេតុផលមានភាពច្បាស់លាស់ណាស់។ វាមិនយុត្តិធម៌ឡើយ ប្រសិនបើជនជាប់ចោទត្រូវបានបដិសេធមិនឲ្យមានឱកាសសួរដេញដោលសាក្សីដែលផ្តល់ភស្តុតាងលើបញ្ហាផ្សេងៗទាក់ទងនឹងរឿងក្តីរបស់ជនជាប់ចោទនោះ។

៧. ការិយាល័យសហព្រះរាជអាជ្ញាមានភារកិច្ចបង្ហាញភស្តុតាងដាក់បន្ទុកជនជាប់ចោទតាមបទដ្ឋានព្រហ្មទណ្ឌចាំបាច់មួយ។ ការិយាល័យសហព្រះរាជអាជ្ញាមានភារកិច្ច (១) កំណត់មូលដ្ឋានឧក្រិដ្ឋកម្ម និង (២) បង្ហាញពីទំនួលខុសត្រូវឧក្រិដ្ឋកម្មរបស់ជនជាប់ចោទ ប្រសិនបើរកឃើញមូលដ្ឋានឧក្រិដ្ឋកម្មហើយនោះ។ ដូចនេះ វាជាការខុសឆ្គងប្រសិនបើផ្តោតទៅលើការបដិសេធសិទ្ធិរបស់ជនជាប់ចោទក្នុងការសួរដេញដោលសាក្សីណាមួយដែលត្រូវបានកោះហៅឲ្យផ្តល់ភស្តុតាងទាក់ទងនឹងបញ្ហាណាមួយនៃបញ្ហាទាំងនេះ។

៨. ការិយាល័យសហព្រះរាជអាជ្ញាហាក់បីដូចជាទទួលស្គាល់ទាំងស្រុងថា ជនជាប់ចោទពិតជាមានសិទ្ធិសួរដេញដោលសាក្សីផ្តល់ភស្តុតាងទាក់ទងនឹងសកម្មភាព និងចរិតរបស់ខ្លួន ប៉ុន្តែអះអាងថាសិទ្ធិនេះមិនរួមបញ្ចូលទាំងការសួរដេញដោលសាក្សីដែលបង្ហាញមូលដ្ឋាននៃបទឧក្រិដ្ឋឡើយ។

៩. ការិយាល័យសហព្រះរាជអាជ្ញាមិនបានបញ្ជាក់ឲ្យបានច្បាស់អំពីជំហររបស់ខ្លួនថាតើខ្លួនមានបំណងចង់កោះហៅសាក្សីមួយចំនួន បើមានការអនុញ្ញាត ឬមិនចង់កោះហៅសាក្សីណាម្នាក់សោះមកផ្តល់សក្ខីកម្ម ទាក់ទងនឹងមូលដ្ឋានឧក្រិដ្ឋកម្មទេ និងថាតើខ្លួននឹងស្នើសុំដាក់បញ្ចូលកំណត់ហេតុស្តាប់ចម្លើយសាក្សីធ្វើជាភស្តុតាងទាក់ទងនឹងមូលដ្ឋានឧក្រិដ្ឋកម្ម ឬដើម្បីផ្តល់ការគាំទ្របន្ថែមចំពោះសាក្សីដែលត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្ម ឬយ៉ាងណាទេ។

១០. ការទទួលយកភស្តុតាងមានកំណត់ក្នុងបទប្បញ្ញត្តិនានានៃវិធាន៨៧ នៃវិធានផ្ទៃក្នុង ដែលចែងថាភស្តុតាងទាំងអស់ត្រូវតែទទួលយកដោយឆ្លងកាត់ការពិនិត្យពីភាពពាក់ព័ន្ធ ដែលជាគោលការណ៍ជាសារវ័ន្តដែលត្រូវអនុវត្តចំពោះការជំនុំជម្រះបទឧក្រិដ្ឋទាំងអស់។ ការិយាល័យសហព្រះរាជអាជ្ញាស្នើដោយខុសសុំដាក់បញ្ចូលក្នុងដំណើរការជំនុំជម្រះក្តីនៅ អ.វ.ត.ក នូវបញ្ញត្តិក្នុងលក្ខន្តិកៈនានាដែលអង្គជំនុំជម្រះបានប្រើក្នុងយុត្តាធិការដ៏ទៃទៀតដែលមានលក្ខណៈខុសគ្នាពីយុត្តាធិការរបស់ អ.វ.ត.ក ហើយនីតិវិធីនៃអង្គជំនុំជម្រះទាំងនោះត្រូវធ្វើឡើងដោយផ្អែកលើប្រព័ន្ធប្រតិប័ក្សនៃច្បាប់ខំមិនឡ។

១១. វិធាន៨៤(១) នៃវិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា ជនជាប់ចោទអាចសួរដេញដោលសាក្សីណាមួយ

ដែលគាត់មិនទាន់មានឱកាសសួរតទល់នៅដំណាក់កាលមុនសវនាការ។ នៅក្នុងសំណុំរឿងបច្ចុប្បន្ន មេធាវីការពារក្តីត្រូវបានហាមឃាត់មិនឲ្យស្តាប់ចម្លើយសាក្សីណាមួយក្នុងដំណាក់កាលនៃការស៊ើបសួរទេ ពីព្រោះការិយាល័យសហចៅក្រមស៊ើបអង្កេតធ្វើការសម្រេចតាមការប៉ាន់ស្មានក្នុងការស្តាប់ចម្លើយសាក្សីដោយគ្មានវត្តមានភាគីនានា។ នៅក្នុងការសម្រេចនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេតប្រាកដជាបានគិតថា ជនជាប់ចោទមានសិទ្ធិសួរដេញដោលនៅដំណាក់កាលនៃការជំនុំជម្រះក្តី អនុលោមតាមវិធាន ៨៤(១) ដែលរារាំងមិនឲ្យរើសអើងចំពោះជនជាប់ចោទតាមរយៈការមិនឲ្យគាត់មានលទ្ធភាពអាចសួរតទល់នៅក្នុងដំណាក់កាលមុនសវនាការ។ ការអនុវត្តនីតិវិធីនេះធ្វើឲ្យចម្លើយទទួលបានពីការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស មិនមានការចូលរួមរបស់មេធាវីការពារក្តីដែលមិនមានឱកាសសួរដេញដោលខ្លឹមសារនៃកំណត់ហេតុទាំងនេះលើបញ្ហាពាក់ព័ន្ធនឹងជនជាប់ចោទនោះទេ។

## ៣.២ សហព្រះរាជអាជ្ញាត្រូវបានហាមឃាត់មិនឲ្យលើកឡើងទឡ្ហីករណ៍មួយនេះឡើយ

១២. ក្នុងដំណាក់កាលស៊ើបអង្កេត មេធាវីការពារក្តីសហជនជាប់ចោទ នួន ជា បានលើកបញ្ហាមួយនេះរួចហើយ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងមកមេធាវីការពារក្តីវិញថា នៅពេលសវនាការ មេធាវីការពារក្តីនឹងអាចសួរដេញដោលសាក្សី[៦]។ នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីនោះ គឺនៅពេលដែលមេធាវីការពារក្តីលើកឡើងពីការព្រួយបារម្ភយ៉ាងខ្លាំងរបស់ខ្លួនដែលថាខ្លួនមិនអាចត្រួតពិនិត្យភស្តុតាងដ៏សំខាន់ដែលដាក់បន្ទុកដល់ជនជាប់ចោទ សហព្រះរាជអាជ្ញាមិនបានបង្ហាញថា ខ្លួនមានចេតនាក្នុងការដាក់កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ដើម្បីធ្វើជាភស្តុតាងនោះឡើយ ដែលការធ្វើដូច្នេះគឺជាការបដិសេធមិនផ្តល់ឱកាសឲ្យមេធាវីការពារក្តីសួរដេញដោលសាក្សីឡើយ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតបានសម្រេចទៅលើបញ្ហានេះដោយមិនគិតដល់ចេតនារបស់សហព្រះរាជអាជ្ញាក្នុងការដាក់កំណត់ហេតុជាលាយលក្ខណ៍អក្សរដើម្បីធ្វើជាភស្តុតាង ដោយមិនបានផ្តល់សិទ្ធិដល់មេធាវីការពារក្តីក្នុងការសួរដេញដោលសាក្សីនៅក្នុងតុលាការឡើយ។ ដោយមិនបានលើកឡើងនៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីនោះ សហព្រះរាជអាជ្ញាបានរក្សាទុកព័ត៌មានដ៏សំខាន់មិនឲ្យទៅសហចៅក្រមស៊ើបអង្កេត។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាគួរត្រូវបានហាមឃាត់មិនឲ្យស្នើសុំដាក់កំណត់ហេតុជាលាយលក្ខណ៍អក្សរ

[៦] លិខិតរបស់ ក.ស.ច.ស ផ្ញើជូនមេធាវីការពារក្តី នួន ជា ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨, ឯកសារលេខ A110/I ទំព័រ២។

របស់ ក.ស.ច.ស ដើម្បីធ្វើជាភស្តុតាងក្នុងពេលនេះឡើយ។ វាមិនមែនជាការមិនសមហេតុផលទេក្នុងការសន្និដ្ឋានថា ប្រសិនបើសហព្រះរាជអាជ្ញាបានបង្ហាញពីចេតនារបស់ខ្លួន ពេលនោះសហចៅក្រមស៊ើបអង្កេតនឹងបានសម្រេចអនុញ្ញាតឲ្យមានការសួរដេញដោលសាក្សីនៅដំណាក់កាលមុនពេលសវនាការមិនខាន។

## ៣.៣ កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស មិនអាចស្មើនឹង “ចម្លើយសាក្សី”ទេ

១៣. ជាងនេះទៀត មេធាវីការពារក្តីលើកអំណះអំណាងថា សហព្រះរាជអាជ្ញាព្យាយាមដោយខុសក្នុងការកំណត់ថា កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស មានតម្លៃដូចគ្នានឹង “ចម្លើយសាក្សី” ដែលពេលខ្លះអាចត្រូវបានទទួលយកធ្វើជាភស្តុតាងដោយមិនចាំបាច់កោះហៅសាក្សីរូបនោះមកផ្តល់សក្ខីកម្មនៅក្នុងយុត្តាធិការផ្សេងៗ។

១៤. ឯកសារដែលជាកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស និងជាឯកសារដែលសហព្រះរាជអាជ្ញាចាត់ទុកថាជា “ចម្លើយសាក្សី” ត្រូវបានចងក្រងក្នុង *កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី (procès-verbal)*[៧]។ មេធាវីការពារក្តីសន្និដ្ឋានថា គុណភាព និងលក្ខណៈនៃឯកសារទាំងនេះ មានភាពខុសគ្នាយ៉ាងខ្លាំងពី “ចម្លើយសាក្សី”។ មេធាវីការពារក្តីសន្និដ្ឋានថា វាមិនយុត្តិធម៌ឡើយសម្រាប់ជនជាប់ចោទ និងជាការបំពានដល់មាត្រា១៤នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (និង មាត្រា៦នៃអនុសញ្ញាសហគមន៍អឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECHR) ក្នុងការអនុញ្ញាតឲ្យដាក់បញ្ចូលកំណត់ហេតុជាលាយលក្ខណ៍អក្សរដើម្បីធ្វើជាភស្តុតាងដោយគ្មានប្រតិចារឹកពេញលេញ និងបន្ទាប់មកបដិសេធសិទ្ធិរបស់ជនជាប់ចោទមិនឲ្យសួរដេញដោលសាក្សីទាក់ទងនឹងផ្នែកពាក់ព័ន្ធទាំងអស់នៃកំណត់ហេតុរបស់សាក្សីទាំងនោះ។

១៥. អ្នកស៊ើបអង្កេតពី ក.ស.ច.ស បានធ្វើការស្តាប់ចម្លើយសាក្សី និងធ្វើការថតសម្លេងតាមខ្សែអាត់សម្លេងពីបទសម្ភាសន៍ជាភាសាដើម។ ដោយមិនធ្វើប្រតិចារឹកពេញលេញនៃការស្តាប់ចម្លើយសាក្សី អ្នកស៊ើបអង្កេតជាញឹកញាប់ធ្វើសេចក្តីសង្ខេបដោយផ្អែកលើការបកស្រាយផ្ទាល់ខ្លួនពីការស្តាប់ចម្លើយបន្ទាប់ពីបានពិភាក្សាជាមួយនឹងសាក្សី និងភាពពាក់ព័ន្ធនៃចម្លើយសាក្សីនោះ។ ចុងក្រោយ កំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងនេះរបស់ ក.ស.ច.ស ត្រូវបានដាក់បន្ថែមទៅក្នុង

[៧] ពីព្រោះ កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស បានប្រើពាក្យ “កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី”។

សំណុំរឿង ហើយនៅពេលនេះ សហព្រះរាជអាជ្ញាចាត់ទុកកំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងនេះថាជា "ចម្លើយសាក្សី"។ មេធាវីការពារក្តីសន្និដ្ឋានថា ពាក្យ "ចម្លើយសាក្សី" នេះមិនតំណាងឲ្យបានត្រឹមត្រូវនូវឯកសារដែលជាកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ទេ ពីព្រោះ ថា ឯកសារទាំងនេះមិនមែនជា "ចម្លើយ"របស់សាក្សីឡើយ។

១៦. សហព្រះរាជអាជ្ញាអះអាងដោយមានទំនុកចិត្តថា "ចម្លើយ" (កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ក.ស.ច.ស) "*មានតម្លៃភស្តុតាងនីយភាព និងបង្ហាញអំពីភាពជឿទុកចិត្តបានច្បាស់លាស់*"[៨]។ មេធាវីការពារក្តីបានធ្វើការពិនិត្យអំពីភាពត្រឹមត្រូវនៃការអះអាងនេះដើម្បីបញ្ជាក់ថាតើសេចក្តីសង្ខេបទាំងនោះត្រឹមត្រូវឬយ៉ាងទេ។ មេធាវីការពារក្តីពុំមានលទ្ធភាពត្រួតពិនិត្យខ្សែអាត់សម្លេងទាំងអស់បានឡើយក្នុងរយៈពេល និងធនធានរបស់ខ្លួន ពីព្រោះចម្លើយសាក្សីមានចំនួនច្រើនសន្ធឹកសន្ធាប់ និងវែងៗ។ ទោះជាយ៉ាងនេះក្តី មេធាវីការពារក្តីបានជ្រើសរើសគំរូនៃកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ដែលបានដាក់ក្នុងសំណុំរឿង និងបានប្រៀបធៀបកំណត់ហេតុទាំងនេះជាមួយនឹងខ្សែអាត់សម្លេងដើមពីបទសម្ភាសន៍ដើម្បីឲ្យដឹងថាតើកំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងនេះអាចចាត់ទុកជាតំណាងត្រឹមត្រូវនៃបទសម្ភាសន៍នោះឬទេ។ ការប្រៀបធៀបនេះបង្ហាញឲ្យឃើញថា កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ជាទូទៅមានភាពមិនត្រឹមត្រូវ, ហាក់ដូចជាដកចេញភស្តុតាងដោះបន្ទុក និងជាញឹកញាប់មិនបានកំណត់អត្តសញ្ញាណប្រភពព័ត៌មានដើមឡើយ។

១៧. ប្រសិនបើមេធាវីការពារក្តីមិនត្រូវបានផ្តល់ឱកាសឲ្យសួរដេញដោលសាក្សីក្នុងអំឡុងពេលនៃដំណើរការជំនុំជម្រះក្តីទេនោះ មេធាវីការពារក្តីមិនអាចកែតម្រូវកំហុសឆ្គង ឬចំណុចខ្វះខាតដែលមាននៅក្នុងកំណត់ត្រានោះ រួមទាំងការខកខានមិនបានដាក់បញ្ចូលភស្តុតាងដោះបន្ទុកផងនោះ។ ដូចនេះ ជនជាប់ចោទអាចត្រូវបានបដិសេធមិនឲ្យទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ ទោះបី "ចម្លើយ" ទាំងនេះ មាន ឬមិនមានទំនាក់ទំនងទៅនឹងភស្តុតាងពីមូលដ្ឋានឧក្រិដ្ឋកម្មក៏ដោយ ឬ ចម្លើយទាំងនេះត្រូវបានសន្មតថាមានភស្តុតាងស្តីពីអំពើ និងចរិតរបស់ជនជាប់ចោទនោះក៏ដោយ ក៏គ្មានអ្វីខុសគ្នានោះទេ។ អង្គហេតុដែលថា ភស្តុតាងពីមូលដ្ឋាននៃបទឧក្រិដ្ឋ អាចយកមកអនុវត្តដោយផ្ទាល់បានតិចតួចចំពោះជនជាប់ចោទ ក៏វាមិនបន្ថយសារៈសំខាន់

---

[៨] សំណើរបស់ ក.ស.ព, កថាខណ្ឌ ៣៨។

នៃភស្តុតាងនេះចំពោះជនជាប់ចោទនោះទេ។ ប្រសិនបើកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ពីមូលដ្ឋាននៃបទឧក្រិដ្ឋ ត្រូវបានអនុញ្ញាតឲ្យដាក់បញ្ចូលធ្វើជាភស្តុតាងដោយមិនអនុញ្ញាតឲ្យមេធាវីការពារក្តីសួរដេញដោលដល់អ្នកផ្តល់ភស្តុតាងទេនោះ វានឹងមានផលប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ។

## ៣.៤ ការវិភាគអង្គហេតុលើកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស

១៨. មេធាវីការពារក្តីដាក់ភ្ជាប់មកជាមួយនូវ **ឧបសម្ព័ន្ធ ក** ដែលបង្ហាញអំពីឧទាហរណ៍នៃភាពមិនស៊ីចង្វាក់គ្នាមួយចំនួនរវាង "កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស" និងការរៀបរាប់ពិតប្រាកដរបស់សាក្សីដែលបានថតក្នុងខ្សែអាត់សម្លេង[៥]។

១៩. ដោយសារគ្មានពេលវេលា និងធនធានគ្រប់គ្រាន់ មេធាវីការពារក្តីអាចមានលទ្ធភាពធ្វើការប្រៀបធៀបតែផ្នែកមួយចំនួនក្នុងកំណត់ហេតុស្តាប់ចម្លើយដែលមានទំនាក់ទំនងខ្លាំងទៅនឹងរឿងក្តីរបស់ជនជាប់ចោទប៉ុណ្ណោះ។ ក្នុងករណីមួយចំនួន លំដាប់លំដោយបញ្ហានៅក្នុង "កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស" គឺមានលក្ខណៈខុសគ្នាទាំងស្រុងពីលំដាប់លំដោយនៃការសម្ភាសន៍ជាក់ស្តែង ដែលបញ្ហានេះធ្វើឲ្យមេធាវីការពារក្តីមិនអាចធ្វើការផ្ទៀងផ្ទាត់ពីភាពត្រឹមត្រូវ និងភាពអាចជឿជាក់បាននៃកំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស បានឡើយ។

២០. មេធាវីការពារក្តីសន្និដ្ឋានថា ការប្រៀបធៀបខ្លឹមសារក្នុងខ្សែអាត់សម្លេងដើមជាមួយនឹងកំណត់ហេតុជាយលក្ខណ៍អក្សរ ដូចមានបញ្ជាក់ក្នុង**ឧបសម្ព័ន្ធ ក** បង្ហាញថា កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស មិនមែនតំណាងដោយយុត្តិធម៌ និងត្រឹមត្រូវ ឬតំណាងឲ្យបានគ្រប់គ្រាន់នៃព័ត៌មានដែលសាក្សីបានផ្តល់ឲ្យឡើយ។ ជាងនេះទៀត ពេលខ្លះ ព័ត៌មានដោះបន្ទុកមិនត្រូវបានសរសេរបញ្ចូលឡើយ។ មេធាវីការពារក្តីគ្មានមូលហេតុណាមួយក្នុងការសន្និដ្ឋានថា គំរូកំណត់ត្រាដែលបានជ្រើសរើសនេះមិនឆ្លុះបញ្ចាំងអំពីលក្ខណៈនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរផ្សេងៗទៀតដែលមិនត្រូវបានឆ្លងកាត់ការប្រៀបធៀបកំណត់ត្រាជាមួយនឹងខ្សែអាត់សម្លេងពេញពីការស្តាប់ចម្លើយសាក្សីឡើយ។

---

[៥] ការបកប្រែខ្សែអាត់សម្លេងពីភាសាខ្មែរជាភាសាអង់គ្លេស និងពីភាសាបារាំងទៅភាសាអង់គ្លេសត្រូវបានធ្វើឡើងដោយក្រុមមេធាវីការពារក្តី។

២១. ឧទាហរណ៍ដែលបានផ្តល់ជូនក្នុង **ឧបសម្ព័ន្ធ ក** បង្ហាញផងដែរថា ជាញឹកញាប់ ព័ត៌មានក្នុងសេចក្តីសង្ខេបបានមកពីអ្នកស៊ើបអង្កេត ឬពីអ្នកបកប្រែភាសា ហើយគ្រាន់តែត្រូវបានបញ្ជាក់បន្ថែមពីសាក្សី ហើយដូចនេះសេចក្តីសង្ខេបនោះផ្អែកលើសំណួរដែលនាំទៅចម្លើយដែលអ្នកសួរចង់បាន។ ការធ្វើដូចនេះមិនមែនជាវិធីសមស្របមួយដែលត្រូវប្រើប្រាស់សម្រាប់ទទួលបានការរៀបរាប់របស់សាក្សីឡើយ។ ការប្រើប្រាស់វិធីសាស្ត្រនេះដើម្បីយកចម្លើយ ធ្វើឲ្យគេមិនអាចកំណត់អត្តសញ្ញាណតាមរយៈចំណុចយោងក្នុង ប្រតិចារឹក ឬខ្សែអាត់សម្លេង ថាតើព័ត៌មានមានប្រភពពីនរណា ឬក៏មិនអាចបញ្ជាក់ថាតើសាក្សីពិតជាបានយល់នូវអ្វីដែលខ្លួនបានធ្វើបញ្ជាក់ដែរឬទេ និងឲ្យដឹងថាតើសាក្សីពិតជាឯកភាពជាមួយព័ត៌មាននោះក្នុងកម្រិតណាឡើយ។ ដូច្នេះ ចម្លើយរបស់ ក.ស.ព មិនអាចចាត់ទុកជាតំណាងត្រឹមត្រូវនៃភស្តុតាងដែលសាក្សីបានផ្តល់ឡើយ។

## ៣.៥ ភាពអាចទទួលយកបាននៃភស្តុតាង

២២. នៅពេលពិចារណាពីភាពអាចទទួលយកបាននៃភស្តុតាង តុលាការសិទ្ធិមនុស្សអឺរ៉ុប (**ECtHR**) បានសម្រេចថា "គុណភាពនៃភស្តុតាងត្រូវតែលើកយកមកពិចារណា ក្នុងនោះរួមមានថាតើកាលៈទេសៈនៃការទទួលបានភស្តុតាងនេះ នាំឲ្យមានការមន្ទិលសង្ស័យអំពីភាពទុកចិត្តបាន ឬភាពត្រឹមត្រូវនៃភស្តុតាង"[១០]។ ដោយផ្អែកលើខ្លឹមសារនេះហើយដែលមេធាវីការពារក្តីសន្និដ្ឋានថា ប្រតិចារឹកពេញលេញគឺជាការចាំបាច់ដើម្បីបញ្ជាក់ពីភាពទុកចិត្តបាន និងភាពត្រឹមត្រូវនៃព័ត៌មានក្នុង "កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់ ក.ស.ចៅ.ស"។ ទាក់ទងនឹងការថតខ្សែអាត់សម្លេងក្នុងពេលស្តាប់ចម្លើយសាក្សី តុលាការ ECtHR បានសម្រេចថែមទៀតថា[១១]៖

> ការថតខ្សែអាត់សម្លេងក៏អាចឲ្យ [ជនជាប់ចោទ] សង្កេតពីលក្ខណៈនៃការស្តាប់ចម្លើយ និងវាយតម្លៃដោយខ្លួនឯងយ៉ាងហោចណាស់ពីភាពអាចជឿជាក់បាននៃការរៀបរាប់របស់សាក្សី។ [...] ទោះបីជាតុលាការទទួលស្គាល់ពីភាពចាំបាច់នៃការថតខ្សែអាត់សម្លេងជាភស្តុតាងក៏ដោយ [...] ក៏ភស្តុតាងតែមួយមុខមិនអាចចាត់ទុកថាអាចការពារសិទ្ធិមេធាវីការពារក្តីបានគ្រប់គ្រាន់ឡើយ ប្រសិនបើមេធាវីការពារក្តីគ្មានឱកាសពិត

---

[១០] *រឿងក្តី A.S. តទល់នឹង ប្រទេសហ្វាំងឡង់,* តុលាការ ECtHR, ឯកសារយោង ២៩ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ ៥២។

[១១] *រឿងក្តី A.S. តទល់នឹង ប្រទេសហ្វាំងឡង់,* តុលាការ ECtHR, ឯកសារយោង២៩ នៃសំណើរបស់ក.ស.ព, កថាខណ្ឌ ៦៦។

ប្រាកដក្នុងការចោទសួរសាក្សីដែលបានរៀបរាប់ដល់សមត្ថកិច្ច [...]។

### *៣.៥.១ យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប*

២៣. យុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលសហព្រះរាជអាជ្ញាបានដកស្រង់នៅក្នុងសំណើរបស់ខ្លួន ទាក់ទិននឹងបញ្ហាថាតើ "ចម្លើយ" ពិតប្រាកដ អាចត្រូវបានទទួលយកដោយសមស្របជាភស្តុតាង និងមិនមែនជាកំណត់ហេតុនៃការស្តាប់ចម្លើយ ដូចក្នុងករណីនេះដែរឬទេ។ មេធាវីការពារក្តីសូមធ្វើការពិនិត្យឡើងវិញដោយសង្ខេបនូវឯកសារសំអាងផ្លូវច្បាប់នានា ដែលសហព្រះរាជអាជ្ញាបានដកស្រង់[១២]។

២៤. រឿងក្តី Unterpertinger *តទល់នឹង ប្រទេសអូទ្រីស្ត*[១៣] ពាក់ព័ន្ធនឹងបុរសម្នាក់ដែលត្រូវបានចោទប្រកាន់ថាបានវាយប្រហារទៅលើកូនស្រីចុងរបស់ខ្លួន។ អតីតប្រពន្ធ និងកូនស្រីចុងរបស់គាត់បានផ្តល់ចម្លើយដល់នគរបាល។ ទោះជាយ៉ាងណាក្តី បើតាមច្បាប់ប្រទេសអូទ្រីស្ត ក្នុងនាមជាគ្រួសាររបស់ជនជាប់ចោទ ពួកគេមិនអាចត្រូវបានបង្ខំឲ្យផ្តល់សក្ខីកម្មនៅក្នុងតុលាការទេ។ ជនជាប់ចោទបានជំទាស់ចំពោះភាពទុកចិត្តបាននៃចម្លើយនោះ។ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានលើកឡើងថា៖

> អាស្រ័យហេតុនេះ បទប្បញ្ញត្តិ [នៅក្នុងច្បាប់ប្រទេសអូទ្រីស្តដែលអនុញ្ញាតឲ្យជនរងគ្រោះមិនផ្តល់សក្ខីកម្មនៅតុលាការនោះ] មិនបានផ្ទុយទៅនឹងមាត្រា៦ öö ១ និង ៣(ឃ) (មាត្រា៦-១ មាត្រា៦-៣-គ) នៃអនុសញ្ញាទេ ដែលចែងថា៖ ចំពោះបញ្ហាពិសេស អាចមានការអនុញ្ញាតឲ្យមានការសួរដេញដោលតទល់គ្នារវាងអ្នកដែល "ត្រូវបានចោទប្រកាន់ពីបទល្មើស" និងសាក្សីដែលជាសមាជិកគ្រួសារគាត់ ហើយត្រូវមានការការពារសាក្សីនោះដោយបញ្ចៀសមិនឲ្យគាត់ត្រូវទទួលរងនូវទុក្ខគ្រោះផ្នែកផ្លូវចិត្ត [...][១៤]។

---

[១២] សំណើរបស់ ក.ស.ព, ជើងទំព័រ១១។

[១៣] សូមមើល ឯកសារយោង៣៣ នៃសំណើរបស់ ក.ស.ព។

[១៤] *រឿងក្តី* Unterpertinge *តទល់នឹង ប្រទេសអូទ្រីស្ត*, តុលាការ ECtHR, ឯកសារយោង៣៣ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៣០។

២៥. សំខាន់ជាងនេះទៀត តុលាការបានសម្រេចថា ដោយសារភស្តុតាងនោះក្លាយជាភស្តុតាងចម្បង ដែលការចោទប្រកាន់ត្រូវលើកយកមកធ្វើជាសំអាងនោះ ពិតជាមានការរំលោភបំពានដល់មាត្រា៦ (១) នៃអនុសញ្ញារបស់សហគមន៍អឺរ៉ុបស្តីពីសិទ្ធិមនុស្សមែន[១៥]។

២៦. នៅក្នុងសារណារបស់ខ្លួន សហព្រះរាជអាជ្ញាក៏បានយោងផងដែរនូវរឿងក្តី *Windisch តទល់នឹង ប្រទេសអូទ្រីស្ត*[១៦]។ ជាថ្មីម្តងទៀត តុលាការសិទ្ធិមនុស្សអឺរ៉ុប បានសម្រេចថា មានការរំលោភបំពានដល់គោលការណ៍នៃការទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដូចមានចែងក្នុង មាត្រា ៦(១) និង ៦(៣)(ឃ) នៃអនុសញ្ញារបស់សហគមន៍អឺរ៉ុបស្តីពីសិទ្ធិមនុស្ស។ សាក្សីអនាមិកពីរនាក់មិនត្រូវបានតម្រូវឲ្យផ្តល់សក្ខីកម្មនៅក្នុងតុលាការទេ ហើយវិធីសាស្ត្រតែមួយដែលជនជាប់ចោទអាចធ្វើការសាកល្បងទៅលើភស្តុតាងនោះគឺ ការធ្វើសម្ភាសន៍ចំពោះមន្ត្រីនគរបាល ដែលធ្លាប់បានស្តាប់ចម្លើយពីសាក្សីទាំងពីររូបនោះមុនពេលសវនាការ[១៧]។

២៧. រឿងក្តីមួយទៀតដែលសហព្រះរាជអាជ្ញាយកមកសំអាងដែរគឺ *រឿងក្តី Delta តទល់នឹង ប្រទេសបារាំង* ដែលតុលាការអឺរ៉ុបបានកំណត់នូវគោលការណ៍នានាដូចខាងក្រោម[១៨]៖

> ៣៦. ជាគោលការណ៍ ភស្តុតាងត្រូវតែបានបង្ហាញឡើងដោយមានវត្តមានរបស់ជនជាប់ចោទនៅក្នុងសវនាការសាធារណៈ ដោយមានការលើកជាទឡ្ហីករណ៍តទល់គ្នាផង។ ទោះជាយ៉ាងណាក្តី ចំណុចនេះមិនមែនមានន័យថា ដើម្បីអាចប្រើប្រាស់ជាភស្តុតាងបាននោះជានិច្ចកាល ចម្លើយរបស់សាក្សីគួរតែត្រូវធ្វើនៅក្នុងពេលសវនាការជាសាធារណៈនៅក្នុង

---

[១៥] *រឿងក្តី Unterpertinge តទល់នឹង ប្រទេសអូទ្រីស្ត*, តុលាការ ECtHR, ឯកសារយោង៣៣ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៣៣។

[១៦] *រឿងក្តី Windisch តទល់នឹង ប្រទេសអូទ្រីស្ត*, តុលាការ ECtHR, ឯកសារយោង៣៥ នៃសំណើរបស់ ក.ស.ព។

[១៧] *រឿងក្តី Windisch តទល់នឹង ប្រទេសអូទ្រីស្ត*, តុលាការ ECtHR, ឯកសារយោង៣៥ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ ២៨។

[១៨] *រឿងក្តី Delta តទល់នឹង ប្រទេសបារាំង*, តុលាការ ECtHR, ឯកសារយោង៣០ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៣៦។ ទឡ្ហីករណ៍ដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុង *រឿងក្តី Asch តទល់នឹង ប្រទេសអូទ្រីស្ត*, ឯកសារយោង២៨ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ២៧; *រឿងក្តី Saïdi តទល់នឹង ប្រទេសបារាំង*, តុលាការ ECtHR, ឯកសារយោង៣២ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៤៣; *រឿងក្តី Van Mechelen និងអ្នកដទៃទៀត តទល់នឹង ប្រទេសហូឡង់*, តុលាការ ECtHR, ឯកសារយោង៣៤ នៃសំណើរបស់ ក.ស.ព។

> តុលាការទេ៖ ក្នុងការប្រើជាភស្តុតាងចម្លើយដែលទទួលបានក្នុងដំណាក់កាលមុនសវនាការ មិនបានផ្ទុយទៅនឹងកថាខណ្ឌ៣(ឃ) និង ១ នៃមាត្រា៦ (មាត្រា៦-៣-ឃ មាត្រា៦-១) ទេ ឲ្យតែសិទ្ធិរបស់ចុងចោទទទួលបានការគោរព។ តាមច្បាប់ សិទ្ធិទាំងនោះតម្រូវថា ជនជាប់ចោទគួរត្រូវបានគេផ្តល់ឱកាសពេញលេញ និងសមរម្យ ដើម្បីជំទាស់ និងសាកសួរដល់សាក្សីដាក់បន្ទុកបាន ទាំងក្នុងពេលដែលសាក្សីនោះបានផ្តល់ចម្លើយក្តី ទាំងនៅក្នុងដំណាក់កាលបន្តបន្ទាប់មកទៀតនៃកិច្ចដំណើរការនីតិវិធីក្តី [...]។

២៨. នៅក្នុងរឿងក្តីនេះ និងផ្ទុយពី *រឿងក្តី Unterpertinger តទល់នឹងប្រទេសអូទ្រីស្ត៍*[១៩] ផងដែរ តុលាការនេះបានសម្រេចថា តាមពិត សាក្សីអាចត្រូវបង្ខំឲ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ[២០]។ ជាថ្មីម្តងទៀត តុលាការអឺរ៉ុបបានសន្និដ្ឋានថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ ត្រូវបានរំលោភបំពាន និងបានលើកឡើងថា[២១]៖

> អាស្រ័យហេតុនេះ ទាំងអ្នកដាក់ពាក្យសុំ ទាំងមេធាវីរបស់ខ្លួន មិនមានឱកាសពេញលេញក្នុងការសួរដេញដោលសាក្សីដែលបង្ហាញភស្តុតាងនេះដោយពុំមានវត្តមានរបស់ពួកគេ ហើយបន្ទាប់មកភស្តុតាងនោះត្រូវបានរាយការណ៍ដោយនគរបាលដែលមិនបានឃើញការវាយប្រហារនៅជាន់ក្រោមដីទេ ដែលត្រូវបានយកមកពិចារណាដោយតុលាការដែលទទួលខុសត្រូវក្នុងការវិនិច្ឆ័យទៅលើអង្គហេតុនានា នៅសាលាដំបូង និងលើបណ្តឹងឧទ្ធរណ៍ ថាសំណុំរឿងនេះមិនមានភស្តុតាងណាផ្សេងទៀតទេ។ អាស្រ័យហេតុនេះ ពួកគេមិនអាចពិនិត្យនូវភាពដែលអាចទុកចិត្តបានរបស់សាក្សីទេ ឬសង្ស័យចំពោះភាពដែលអាចជឿជាក់បានដែរ។

២៩. នៅក្នុង *រឿងក្តី Asch តទល់នឹង ប្រទេសអូទ្រីស្ត៍*[២២] តុលាការសិទ្ធិមនុស្សអឺរ៉ុប បានសម្រេចថា ទោះបីតុលាការក្នុងស្រុកមិនអាចស្តាប់ចម្លើយជនរងគ្រោះសំខាន់ក៏ដោយ ក៏ចំណុចនេះមិនបណ្តាលឲ្យមានការរំលោភដល់សិទ្ធិចុងចោទដែរ ដោយសារមន្ត្រីដែលបានសាកសួរយកចម្លើយពីសាក្សីមុនដំណាក់កាលសវនាការនោះត្រូវបានកោះហៅនៅដំណាក់កាលសវនាការ ហើយទីពីរ ដោយសារ

---

[១៩] សូមមើល ឯកសារយោង៣៣ នៃសំណើរបស់ ក.ស.ព។

[២០] *រឿងក្តី Delta តទល់នឹង ប្រទេសបារាំង*, តុលាការ ECtHR, ឯកសារយោង៣០ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៣៧។

[២១] *រឿងក្តី Delta តទល់នឹង ប្រទេសបារាំង*, តុលាការ ECtHR, ឯកសារយោង៣០ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៣៧។

[២២] *រឿងក្តី Asch តទល់នឹង ប្រទេសអូទ្រីស្ត*, តុលាការ ECtHR, ឯកសារយោង២៨ នៃសំណើរបស់ ក.ស.ព។

មានភស្តុតាងជាច្រើនទៀតដែលគាំទ្រដល់ការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទដែរ។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា នេះជាករណីនៃអំពើហិង្សាក្នុងគ្រួសារ ដែលស្ត្រីជាជនរងគ្រោះ ត្រូវបានវាយប្រហារនៅក្នុងផ្ទះរបស់ខ្លួន ដោយសារស្វាមីរបស់ខ្លួនគឺលោក Asch។ នាពេលព្រឹកបន្ទាប់ពីការវាយប្រហារនោះ ជនរងគ្រោះបានទៅជួបនគរបាល និងវេជ្ជបណ្ឌិត និងបានធ្វើកំណត់ហេតុស្តីពីព្យសនកម្មដែលគាត់បានទទួលរងកាលពីយប់កន្លងទៅ។ ករណីអំពើហិង្សាក្នុងគ្រួសារមានលក្ខណៈពិសេសដោយឡែក ទាក់ទិននឹងទម្ងន់នៃភស្តុតាង ហើយមិនអាចយកមកប្រៀបធៀបនឹងករណីនេះបានទេ បើទោះបីជាធាតុផ្សំដទៃៗទៀតទាំងអស់នៅក្នុងករណីដោយឡែកនោះមិនត្រូវបានយកមកពិចារណាក៏ដោយ។ តុលាការបានសម្រេចយ៉ាងច្បាស់ថា កត្តាទាំងនេះបានធ្វើឱ្យមានភាពខុសគ្នាស្រឡះរវាងអង្គហេតុនៅក្នុងរឿងក្តី *Asch* និងអង្គហេតុនៅក្នុងរឿងក្តី *Unterpertinger* និង *Delta* ដែលបានលើកមកពិភាក្សាខាងលើ[២៣]។

៣០. បន្ថែមទៅទៀត នៅក្នុងរឿងក្តី *Saïdi តទល់នឹង ប្រទេសបារាំង* តុលាការអឺរ៉ុបបានសម្រេចថា មានការរំលោភបំពានដល់មាត្រា៦ នៃអនុសញ្ញារបស់សហគមន៍អឺរ៉ុបស្តីពីសិទ្ធិមនុស្ស នៅពេលសក្ខីកម្មដែលជាមូលដ្ឋានតែមួយគត់សម្រាប់ឱ្យអ្នកដាក់ពាក្យសុំធ្វើការចោទប្រកាន់នោះ មិនត្រូវបានយកមកពិនិត្យពិច័យក្នុងសវនាការទេ។ តុលាការនេះបានសម្រេចបន្ថែមទៀតថា "កង្វះការសួរតទល់គ្នាបានធ្វើឱ្យចុងចោទបាត់បង់ផ្នែកខ្លះនៃការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌" ហើយបានសម្រេចថា ទោះមានការលំបាកក្នុងការប្រយុទ្ធនឹងការជួញដូរគ្រឿងញៀន ជាពិសេសទាក់ទិននឹងការទទួលបាន និងការបង្ហាញភស្តុតាងបែបនេះក៏ដោយ "ការសន្និដ្ឋានបែបនេះមិនបានផ្តល់យុត្តិកម្មដែលកំហិតត្រឹមតែវិសាលភាពនៃសិទ្ធិរបស់ចុងចោទនេះទេ"[២៤]។

៣១. រឿងក្តី *Van Mechelen និងអ្នកដទៃទៀត តទល់នឹង ប្រទេសហូឡង់* ដែលក៏ត្រូវបានដកស្រង់នៅក្នុងសំណើរបស់ ក.ស.ព ដែរ ដើម្បីគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួន ពាក់ព័ន្ធនឹងការប្រើប្រាស់សាក្សីអនាមិក ហើយតុលាការក្នុងរឿងក្តីនោះបានសម្រេចថា សាក្សីអនាមិកមិនអាចធ្វើជាមូលដ្ឋានតែមួយគត់សម្រាប់ធ្វើការចោទប្រកាន់ទេ[២៥]។ សាក្សីអនាមិកមិនអាចមានទម្ងន់ស្មើជាមួយ

---

[២៣] *រឿងក្តី Asch តទល់នឹង ប្រទេសអូទ្រីស*, តុលាការ ECtHR, ឯកសារយោង២៨ នៃសំណើរបស់ ក.ស.ព។

[២៤] *រឿងក្តី Saïdi តទល់នឹង ប្រទេសបារាំង*, តុលាការ ECtHR, ឯកសារយោង៣២ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៤៤។

[២៥] *រឿងក្តី Van Mechelen និងអ្នកដទៃទៀត តទល់នឹង ប្រទេសហូឡង់*, តុលាការ ECtHR, ឯកសារយោង៣៤ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៥៥។

សាក្សីដែលបានផ្តល់សក្ខីកម្មពីមូលដ្ឋាននៃបទឧក្រិដ្ឋបានទេ។ នៅក្នុងរឿងក្តី *Van Mechelen* បញ្ហាគឺស្ថិតនៅត្រង់ថាចុងចោទមិនមានសិទ្ធិសួរដេញដោលសាក្សីដែលមានបញ្ហានោះទេ ដោយសារពួកគេមានសិទ្ធិនោះហើយ តែគឺថា កិច្ចការនេះត្រូវបានធ្វើឱ្យគ្មានន័យខ្លឹមសារអ្វីទេ ដោយសារថាពួកគេមិនបានដឹងពីអត្តសញ្ញាណរបស់សាក្សីដោយឡែកនោះ[២៦]។ តុលាការនេះបានសម្រេចថា សេចក្តីសម្រេចរបស់តុលាការហូឡង់ក្នុងការអនុញ្ញាតឱ្យមានភស្តុតាងអនាមិក មិនត្រូវបានផ្តល់យុត្តិកម្មឱ្យបានគ្រប់គ្រាន់ទេ ហើយតុលាការនេះបានសន្និដ្ឋានថា មានការរំលោភបំពានដល់មាត្រា៦ នៃអនុសញ្ញារបស់សហគមន៍អឺរ៉ុបស្តីពីសិទ្ធិមនុស្ស ហើយជាថ្មីម្តងទៀត តុលាការនេះបានសង្កត់ធ្ងន់ទៅលើសារៈសំខាន់ដែលមេធាវីការពារក្តីត្រូវសួរដេញដោលសាក្សីក្នុងតុលាការ ហេតុនេះទើបគេអាចវិនិច្ឆ័យនូវភាពទុកចិត្តបាន និងអត្តចរិតរបស់សាក្សីនោះបាន[២៧]។

៣២. នៅក្នុងរឿងក្តី *Lucà តទល់នឹង ប្រទេសអ៊ីតាលី* តុលាការអឺរ៉ុបបានពិចារណាទៅលើបណ្តឹងមួយរបស់ជនជាប់ចោទម្នាក់ដែលត្រូវបានគេដកហូតឱកាសមិនឱ្យធ្វើការសួរដេញដោលទៅលើសាក្សីសំខាន់ ដែលបានផ្តល់ភស្តុតាងសម្រាប់ធ្វើការចោទប្រកាន់ ហើយនៅក្នុងរឿងក្តីនោះ តុលាការបានសម្រេចថាមានការរំលោភបំពានទៅលើមាត្រា៦[២៨]។

៣៣. នៅក្នុងរឿងក្តី *A.S. តទល់នឹង ប្រទេសហ្វាំងឡង់* ដែលពាក់ព័ន្ធដល់ការផ្តល់សក្ខីកម្មរបស់កុមារម្នាក់អាយុ ៥ ឆ្នាំ ប្រឆាំងនឹងចារីមួយរូបដែលត្រូវបានចោទប្រកាន់ពីការរំលោភផ្លូវភេទ។ ដោយសារការសាកសួរសំណួរមានការប៉ះពាល់ទៅលើកុមារបែបនេះ គ្រូពេទ្យផ្នែកកុមារបានសម្រេចថាកុមារនោះមិនគួរត្រូវបានគេសួរសំណួរបន្ថែមទៀតទេ[២៩]។ ពិសេសជាងនេះទៀត រឿងក្តីនេះពាក់ព័ន្ធទៅនឹងសំណួរថាតើ រូបភាពវីដេអូនៃការស្តាប់ចម្លើយកុមារនោះគួរត្រូវបានទទួលយកជាភស្តុតាងឬទេ នៅពេលដែលអ្នកដាក់ពាក្យសុំមិនបានស្តាប់ចម្លើយកុមារនោះដោយខ្លួនឯងបែបនេះ។ ច្បាប់

[២៦] *រឿងក្តី Van Mechelen និងអ្នកដទៃទៀត តទល់នឹង ប្រទេសហូឡង់*, តុលាការ ECtHR, ឯកសារយោង៣៤ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៥៩។

[២៧] *រឿងក្តី Van Mechelen និងអ្នកដទៃទៀត តទល់នឹង ប្រទេសហូឡង់*, តុលាការ ECtHR, ឯកសារយោង៣៤ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៦២។

[២៨] *រឿងក្តី Lucà តទល់នឹង ប្រទេសអ៊ីតាលី*, តុលាការ ECtHR, ឯកសារយោង៣១ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៣៤-៤៥។

[២៩] *រឿងក្តីA.S. តទល់នឹង ប្រទេសហ្វាំងឡង់*, តុលាការ ECtHR, ឯកសារយោង២៩ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ១៣។

ក្នុងប្រទេសហ្វាំងឡង់ចែងថា រូបភាពវីដេអូនៃការស្តាប់ចម្លើយកុមារអាយុក្រោម ១៥ ឆ្នាំ មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ក្នុងតុលាការទេ លុះត្រាតែជនជាប់ចោទមានឱកាសបានស្តាប់ចម្លើយសាក្សីនោះសិន។ ទោះជាយ៉ាងណាក្តី អ្នកដាក់ពាក្យសុំបានយល់ស្របជាមុនទៅនឹងការបង្ហាញរូបភាពវីដេអូនេះក្នុងតុលាការដែរ[៣០]។

៣៤. នៅក្នុងរឿងក្តី *A.S. តទល់នឹង ប្រទេសហ្វាំងឡង់* តុលាការអឺរ៉ុបបានសម្រេចថា[៣១]៖

> នៅគ្រប់កាលៈទេសៈទាំងអស់ កថាខណ្ឌ១ នៃមាត្រា៦ ដែលភ្ជាប់ជាមួយកថាខណ្ឌ៣ តម្រូវឲ្យរដ្ឋភាគីនៃអនុសញ្ញានេះត្រូវចាត់វិធានការដោះស្រាយ ជាពិសេសដើម្បីឲ្យជនជាប់ចោទបានសួរដេញដោលសាក្សីដាក់បន្ទុក។ វិធានការទាំងនេះជាផ្នែកនៃការយកចិត្តទុកដាក់ដែលរដ្ឋភាគីនៃអនុសញ្ញានេះត្រូវអនុវត្ត ដើម្បីធានាថា សិទ្ធិដែលត្រូវបានធានាដោយមាត្រា៦ ត្រូវបានអនុវត្តដោយមានប្រសិទ្ធភាព [...]។

៣៥. ទោះបីនៅក្នុងរឿងក្តី *A.S. តទល់នឹង ប្រទេសហ្វាំងឡង់* ទាក់ទិននឹងបញ្ហាដែលមានលក្ខណៈរសើបនៃការបំពារបំពានផ្លូវភេទទៅលើកុមារ តុលាការអឺរ៉ុបបានសម្រេចថា វិធានការជាក់លាក់មួយចំនួនគួរត្រូវបានយកមកអនុវត្ត ដែលការខកខានមិនបានអនុវត្តនោះនឹងនាំឲ្យមានការរំលោភបំពានដល់អនុសញ្ញានេះ[៣២]៖

> ក្នុងការទទួលស្គាល់នូវតម្រូវការឲ្យមានតុល្យភាពរវាងសិទ្ធិរបស់ចុងចោទ និងសិទ្ធិរបស់ជនរងគ្រោះជាកុមារនោះ តុលាការសន្និដ្ឋានថា ត្រូវមានការធានាអប្បរមាគឺថា៖ ជនជាប់សង្ស័យត្រូវបានទទួលព័ត៌មានស្តីពីសវនាការរបស់កុមារនោះ ខ្លួនត្រូវបានទទួលនូវឱកាសក្នុងការសង្កេតសវនាការនោះ ទោះបីកំពុងដំណើរការក្តី ឬបានដំណើរការរួចហើយៗត្រូវបានថតសម្លេងសោតទស្សន៍ក្តី ហើយគួរមានឱកាសក្នុងការសាកសួរកុមារនោះ ទោះដោយផ្ទាល់ក្តី ដោយប្រយោលក្តី នៅក្នុងដំណាក់នៃសវនាការដំបូងក្តី ឬក្នុងឱកាសដទៃទៀតក្តី។

---

[៣០] *រឿងក្តីA.S. តទល់នឹង ប្រទេសហ្វាំងឡង់*, តុលាការ ECtHR, ឯកសារយោង២៩ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៤៩។
[៣១] *រឿងក្តីA.S. តទល់នឹង ប្រទេសហ្វាំងឡង់*, តុលាការ ECtHR, ឯកសារយោង២៩ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៥៣។
[៣២] *រឿងក្តីA.S. តទល់នឹង ប្រទេសហ្វាំងឡង់*, តុលាការ ECtHR, ឯកសារយោង២៩ នៃសំណើរបស់ ក.ស.ព, កថាខណ្ឌ៥៦។

៣៦. នៅក្នុងរឿងក្ដីនោះ តុលាការនេះបានសន្និដ្ឋានថា យ៉ាងហោចណាស់ អ្នកដាក់ពាក្យសុំគួរមានសិទ្ធិរៀបចំសំណួរជាលាយលក្ខណ៍អក្សរសួរទៅកុមារនោះដែរ។ មេធាវីការពារក្ដីជនជាប់ចោទមិនមានឱកាសក្នុងការរៀបចំសំណួរជាលាយលក្ខណ៍អក្សរបែបនោះទេ។ ប្រសិទ្ធភាពនៃសំណើរបស់ ក.ស.ព គឺដើម្បីបញ្ចូលចម្លើយរបស់សាក្សីជាភស្តុតាង ដោយចម្លើយទាំងនោះ មេធាវីការពារក្ដីមិនទាន់បានពិនិត្យ *ទាល់តែសោះ*។ នីតិវិធីនេះគឺជាការរំលោភដល់សេចក្ដីសម្រេចរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុបដែលកំណត់នូវលក្ខខណ្ឌអប្បបរមាក្នុងការគោរពដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបាននូវការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌។

៣៧. រឿងក្ដីនានាដែលបានលើកឡើងដោយ ក.ស.ព បានបង្ហាញពីសារៈសំខាន់ក្នុងការឲ្យជនជាប់ចោទធ្វើការសួរដេញដោលសាក្សីដែលបានផ្ដល់ភស្តុតាងដាក់បន្ទុក។

### *៣.៥.២ យុត្តាធិការរបស់តុលាការអន្តរជាតិ*

៣៨. នៅតាមបណ្ដាតុលាការអន្តរជាតិនានា មុនពេលចាប់ផ្ដើមសវនាការ មេធាវីការពារក្ដីបានទទួលនូវចម្លើយពេញលេញរបស់សាក្សី ដើម្បីឲ្យមេធាវីការពារក្ដីបានពិនិត្យមើលយ៉ាងពេញលេញទៅលើអ្វីដែលសាក្សីបាននិយាយទៅកាន់អ្នកស៊ើបអង្កេត[៣៣]។ ប្រការនេះអនុញ្ញាតឲ្យមេធាវីការពារក្ដីបានដឹងច្បាស់ពីប្រភពដើមនៃព័ត៌មានដែលមានក្នុងចម្លើយនោះ ដែលផ្ទុយពីនីតិវិធីដែលកំពុងអនុវត្តនៅ អ.វ.ត.ក ចំពោះសំអាងហេតុដូចបានរៀបរាប់ខាងលើ។ ជាងនេះទៀត ដូចដែលការវិភាគជាផ្នែកៗចំពោះខ្សែអាត់សម្លេងនៃការស្ដាប់ចម្លើយបានបង្ហាញស្រាប់ គឺថា ភស្តុតាងដោះបន្ទុកមិនត្រូវបានបញ្ចូលក្នុងកំណត់ហេតុលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ទេ។ ការទទួលយកជាភស្តុតាងដែលមានលក្ខណៈបែបនេះ ដែលគេមិនអាចពិនិត្យបាន នឹងក្លាយជាការរំលោភបំពានដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌មិនខាន។

[៣៣] ទោះបីចម្លើយនោះអាចត្រូវបានកាត់បន្ថយនៅក្នុងដំណាក់កាលដំបូងក៏ដោយ តែប្រការនេះមិនអាចរារាំងមិនឲ្យមេធាវីការពារក្ដីបានដឹងនូវព័ត៌មានពេញលេញនៃព័ត៌មាន (ដោះបន្ទុក) ដែលទាក់ទិននឹងជនជាប់ចោទ ដែលមានរៀបរាប់នៅក្នុងចម្លើយនោះទេ។

៣៩. ហេតុនេះ ការប្រៀបធៀបទៅលើការអនុវត្តស្ដីពីការទទួលយកចម្លើយសាក្សីនៅតុលាការ ICTY តុលាការ ICTR និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន មិនមានប្រយោជន៍ក្នុងការសម្រេចលើបញ្ហានេះទេ។

៤០. ជាងនេះទៀត ទោះបីជាការប្រៀបធៀបជាមួយតុលាការដទៃទៀតអាចមានសារៈប្រយោជន៍ក៏ដោយ តែការយោងទៅដល់វិធាននីតិវិធី និងភស្តុតាង (RPE) របស់តុលាការ ICTY និងតុលាការ SCSL មិនមានប្រយោជន៍ដល់ករណីនេះទេ ដោយសារថា តុលាការទាំងនោះមិនមានវិធានណាមួយដែលសមមូលទៅនឹងវិធាន៨៤(១) នៃវិធានផ្ទៃក្នុង ដែលបានបង្ហាញពីសារៈសំខាន់នៃបទប្បញ្ញត្តិនេះទេ។ ដូចគ្នាផងដែរ ដូចដែលសហព្រះរាជអាជ្ញាបានទទួលស្គាល់រួចមកហើយគឺថា តុលាការដទៃទៀតមានបទប្បញ្ញត្តិច្បាស់លាស់ក្នុងការទទួលយកចម្លើយរបស់សាក្សី[៣៤]។ ការមិនមានចែងនូវបទប្បញ្ញត្តិទាំងនេះនៅក្នុងលិខិតុបករណ៍ច្បាប់នៅ អ.វ.ត.ក ជាការបង្ហាញពីប្រព័ន្ធផ្សេងគ្នាដែលត្រូវបានយកមកអនុវត្ត។ ចំពោះវិធាននានាដែលមានចែងនៅក្នុងលក្ខន្តិកៈតុលាការដទៃ និងការយល់ដឹងរបស់អ្នកតាក់តែងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ការលុបចោលនូវបទប្បញ្ញត្តិច្បាស់លាស់ ដែលអនុញ្ញាតឱ្យមានការទទួលយកចម្លើយជាលាយលក្ខណ៍អក្សរ គឺជាចេតនាមួយ។ សហព្រះរាជអាជ្ញាបានយល់ខុសដែលថាវាជា *ចន្លោះប្រហោង (lacuna)* នៅក្នុងវិធានផ្ទៃក្នុង។

៤១. យុត្តិសាស្ត្រដែលបានដកស្រង់ចេញពីតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) គឺមានភាពពាក់ព័ន្ធតិចតួច ដោយសារថា ដូចតុលាការដទៃទៀតដែរ តុលាការ ICC យក "ចម្លើយរបស់សាក្សី" មកប្រើប្រាស់តែម្ដង ដោយមិនផ្អែកលើសេចក្ដីសង្ខេបនៃចម្លើយនោះទេ។ ទោះជាយ៉ាងណាក្ដី ប្រការដែលគួរឱ្យកត់សម្គាល់នោះគឺថា តុលាការ ICC មិនបានអនុញ្ញាតឱ្យប្រើប្រាស់ចម្លើយរបស់សាក្សីទេ លុះត្រាតែមេធាវីការពារក្ដី និងអយ្យការ បានទទួលឱកាសក្នុងការសួរដេញដោលអ្នកផ្ដល់ចម្លើយនៅពេលដែលចម្លើយនោះបានផ្ដល់។

៤២. សហព្រះរាជអាជ្ញាយោងទៅដល់ "ប្រព័ន្ធស៊ីវិលឡូ" ក្នុងកថាខណ្ឌ៣១ នៃសំណើរបស់ ក.ស.ព។ មេធាវីការពារក្ដីសូមលើកឡើងថា ចាំបាច់ត្រូវមានការប្រយ័ត្នក្នុងការប្រើប្រាស់ពាក្យនោះ ដោយ

---

[៣៤] សូមមើលសំណើរបស់ ក.ស.ព, កថាខណ្ឌ៥។ ទោះបី ក.ស.ព ចាត់ទុកនេះចំណុចជា "*ការចន្លោះប្រហោង*" ក៏ដោយ ក៏មេធាវីការពារក្ដីសន្និដ្ឋានថា ការលុបចោលនូវបញ្ញត្តិនេះនៅក្នុងវិធានមិនមែនជាការមើលរំលងទេ តែជាការសម្រេចចិត្តមួយយ៉ាងទូលំទូលាយ។

ហេតុថាក្នុងប្រព័ន្ធស៊ីវិលឡូមានភាពខុសៗគ្នាជាច្រើន ហើយបើតាមអ្វីដែលមេធាវីការពារក្តីបានដឹងគឺថា នៅក្នុងប្រព័ន្ធភាគច្រើន (បើមិនទាំងអស់ទេ) មេធាវីការពារក្តីត្រូវបានអនុញ្ញាតឲ្យពិនិត្យទៅលើភស្តុតាងរបស់សាក្សី ទាំងនៅក្នុងដំណាក់កាលមុនសវនាការ ទាំងក្នុងតុលាការ។ ទោះបីជានៅក្នុងប្រព័ន្ធស៊ីវិលឡូក្តី ឬខំមិនឡូក្តី ក៏មិនមានប្រព័ន្ធណាមួយដែលមេធាវីមាន "សេរីភាពឥតព្រំដែនក្នុងការសួរតទល់ទៅលើសាក្សី" ដែរ[៣៥] ហើយការកំហិតនានាត្រូវបានធ្វើឡើងដែរ ដូចដែលមានរៀបរាប់នៅក្នុងរឿងក្តីនានានៅតុលាការសិទ្ធិមនុស្សអឺរ៉ុបខាងលើស្រាប់។ ជាងនេះទៀត រឿងក្តីដែលសហព្រះរាជអាជ្ញាបានដកស្រង់ពីឆ្នាំ ១៩៦៩ មកម្ល៉េះ ហើយ "ប្រព័ន្ធស៊ីវិលឡូ" ក៏មានការវិវត្តជាច្រើនណាស់ដែរតាំងពីពេលនោះមក[៣៦]។ មេធាវីការពារក្តីសូមសន្និដ្ឋានថា នៅក្នុងប្រព័ន្ធស៊ីវិលឡូ ជាទូទៅ ជនជាប់ចោទ ឬមេធាវីរបស់ខ្លួន ចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីមុនសវនាការ ទោះបីជនត្រូវចោទប្រើសិទ្ធិនៅស្ងៀមក៏ដោយ។

៤៣. ជាងនេះទៀត ការសង្កត់ធ្ងន់របស់ ក.ស.ព ទៅលើភាពសត្យានុម័តនៃនីតិវិធីដែលអនុវត្តដោយសហចៅក្រមស៊ើបអង្កេត ត្រូវបានជំទាស់ដោយមេធាវីការពារក្តីនៅគ្រប់ពេលក្នុងកិច្ចដំណើរការនីតិវិធីទាំងនោះ។ ទាក់ទិននឹងយោបល់ពីដំបូងៗរបស់មេធាវីការពារក្តីទៅលើគុណភាពនៃកំណត់ហេតុលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស នោះគឺថា វាមិនពាក់ព័ន្ធទៅនឹងបញ្ហាថាតើការភាន់ច្រឡំ និងការលុបចោលនៅក្នុងកំណត់ហេតុលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស គឺបណ្តាលមកពីសកម្មភាពដោយចេតនា ឬគ្រាន់តែជាកំហុសឆ្គង និងភាពមិនត្រឹមត្រូវប៉ុណ្ណោះ។ អ្វីដែលពាក់ព័ន្ធនោះគឺថា វាបង្ហាញឲ្យឃើញថា កំណត់ហេតុលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស មិនបានឆ្លុះបញ្ចាំងដោយត្រឹមត្រូវនូវការស្តាប់យកចម្លើយដែលបានធ្វើចំពោះសាក្សីទាំងនេះទេ ហើយកំណត់ហេតុលាយលក្ខណ៍អក្សរទាំងនោះ មិនអាចទទួលយកបានទេ ប្រសិនបើប្រតិចារឹកទាំងស្រុងមិនត្រូវបានទទួលយកជាភស្តុតាង ឬបើពុំមានការសួរតទល់ពីមេធាវីការពារក្តីនោះ។

៤៤. នៅក្នុងកថាខណ្ឌ៣៤ នៃសំណើរបស់ខ្លួន សហព្រះរាជអាជ្ញាបានអះអាងថា មេធាវីការពារក្តីមានបំណងសួរដេញដោលសាក្សីរាប់រយនាក់ក្នុងពេលសវនាការ។ ចំនួននេះ វាអាស្រ័យទៅលើចំនួនសាក្សីដែលបានកោះហៅដោយសហព្រះរាជអាជ្ញា (ដែលអាចមានរហូតដល់ជាច្រើនរយនាក់) និង

---

[៣៥] សំណើរបស់ ក.ស.ព, កថាខណ្ឌ៣១។

[៣៦] ឯកសារយោង៣៨ នៃសំណើរបស់ ក.ស.ព។

ជាងនេះទៅទៀត គឺវាអាស្រ័យទៅលើចំនួនកំណត់ហេតុលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ដែលសហព្រះរាជអាជ្ញាលើកយកមកសំអាងក្នុងពេលសវនាការ។ សហព្រះរាជអាជ្ញាជាអ្នកជ្រើសរើសឈ្មោះសាក្សីណាដែលខ្លួនចង់កោះហៅ មកដាក់ក្នុងបញ្ជីឈ្មោះសាក្សីរបស់ខ្លួន និងជាអ្នកជ្រើសរើសកំណត់ហេតុលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ដែលខ្លួនមានបំណងបញ្ចូលជាភស្តុតាង។ មេធាវីការពារក្តីគ្រាន់តែអះអាងពីសិទ្ធិរបស់ខ្លួនក្នុងការពិនិត្យទៅលើភស្តុតាងសម្រាប់ចោទប្រកាន់តែប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាបានដាក់ឯកសារចំនួន ៦.៨៦៩ ទៅក្នុងបញ្ជីឯកសាររបស់ខ្លួន ដែលរួមទាំងឯកសារចំនួន ១.៤១៥ ដែលគេហៅថាជា "ចម្លើយសាក្សី"។ មេធាវីការពារក្តីសូមស្នើដោយគោរពថា ប្រសិនបើសហព្រះរាជអាជ្ញាមានកង្វល់ពីដំណើរនៃរឿងក្តីនេះឲ្យបានលឿននោះ ពួកគេអាចមានដំណោះស្រាយសមរម្យ តែមិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទទេ។

៤៥. សហព្រះរាជអាជ្ញាបានដកស្រង់នូវវិធាន២១នៃវិធានផ្ទៃក្នុង។ មេធាវីការពារក្តីសូមលើកឡើងថា បញ្ញត្តិនេះមិនពាក់ព័ន្ធដល់បញ្ហាដែលត្រូវសម្រេចនោះទេ។ សហព្រះរាជអាជ្ញាអាចស្នើសុំឲ្យសាក្សីទាំងអស់បានចូលរួមក្នុងសវនាការ ដែលសាក្សីទាំងនោះបានផ្តល់ភស្តុតាងដែលសហព្រះរាជអាជ្ញាយកធ្វើជាសំអាងក្នុងការការពារទឡ្ហីករណ៍របស់ខ្លួន។

៤៦. មេធាវីការពារក្តីសូមលើកឡើងបន្ថែមទៀតថា សំណុំរឿង០០១ មិនគួរយកមកធ្វើជាមគ្គុទ្ទេសន៍សម្រាប់អង្គជំនុំជម្រះ ក្នុងការសម្រេចសេចក្តីទៅលើបញ្ហានេះក្នុងសំណុំរឿង០០២ ទេ។ រឿងក្តីទាំងពីរនេះខុសគ្នាទាំងស្រុង ហើយមានអង្គហេតុជាច្រើនមិនមាននៅក្នុងសំណុំរឿង០០១ទេ។ អង្គជំនុំជម្រះសាលាដំបូងមានកង្វល់ចំពោះការទទួលយកឯកសារចំនួន ១៤ ជាភស្តុតាង[៣៧]។

## ៣.៦ ចម្លើយដែលទទួលបានពីអង្គការ និងបុគ្គលខាងក្រៅ

៤៧. សហព្រះរាជអាជ្ញាបានអះអាងបន្ថែមទៀតថា "ចម្លើយសាក្សី" ដែលមកពីអង្គការខាងក្រៅ ក្រៅពី ក.ស.ច.ស គួរតែត្រូវបានទទួលយកជាភស្តុតាងដែរ[៣៨] ដូចជាចម្លើយនានាដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ជាដើម។ ដូចដែលបានបង្ហាញរួចមកហើយនៅក្នុងសារណាពី

[៣៧] សំណើរបស់ ក.ស.ព, កថាខណ្ឌ៣០។

[៣៨] សំណើរបស់ ក.ស.ព, កថាខណ្ឌ៣៩។

មុនៗដែលបានដាក់ដោយក្រុមមេធាវីការពារក្ដីដទៃទៀតគឺថា ព័ត៌មានដែលបានមកពីអង្គការនេះ មិនអាចចាត់ទុកថាមានលក្ខណៈសត្យានុម័តបានទេ ហេតុនេះពុំអាចធ្វើឲ្យទុកចិត្តបានទេ។ អង្គការនេះត្រូវបានបង្កើតឡើងដើម្បីជម្រុញឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហម។ ត្រង់ចំណុចនេះ មេធាវីការពារក្ដីសូមយោងទៅដល់សារណាដែលបានដាក់ដោយមេធាវីការពារក្ដីលោក អៀង សារី ដែលជាសហជនជាប់ចោទ ដែលបានស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកុំយកសម្ភារៈដែលបានមកពី DC-Cam មកធ្វើសំអាង[៣៩]។ ទទ្ធីករណ៍សម្រាប់ចំណុចនេះក៏អនុវត្តចំពោះការស្ដាប់ចម្លើយក្នុងការត្រៀមរៀបចំសវនាការដែលបានធ្វើឡើងដោយអង្គការ ឬបុគ្គលដទៃ ដែលចម្លើយទាំងនេះមិនអាចចាត់ទុកថាមានលក្ខណៈសត្យានុម័តនោះទេ។ ជាងនេះទៀត ជាញឹកញយ ប្រភពដើមនៃសម្ភារៈនោះមិនមានភាពច្បាស់លាស់ឡើយ។

### ៣.៧ ការទទួលយកចម្លើយសាក្សីដែលបានស្លាប់

៤៨. សំណើរបស់សហព្រះរាជអាជ្ញាបានយោងទៅដល់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១ ទាក់ទិននឹងការទទួលយកនូវចម្លើយពីសាក្សីដែលពេលនេះគាត់បានស្លាប់បាត់បង់ជីវិតទៅហើយ[៤០]។ ក្នុងករណីនោះ អង្គជំនុំជម្រះបានបដិសេធមិនទទួលយកសំណើរបស់សហព្រះរាជអាជ្ញាក្នុងការទទួលយកជាភស្តុតាងនូវចម្លើយដែលបានផ្ដល់ដោយសាក្សីដែលបានស្លាប់បាត់បង់ជីវិតទៅហើយ ដោយសារថា មេធាវីការពារក្ដីមិនមានឱកាសក្នុងការសាកសួរដេញដោលទៅលើចម្លើយរបស់សាក្សីនោះ ទាំងក្នុងដំណាក់កាលស៊ើបអង្កេត ក៏ដូចជាក្នុងដំណាក់កាលសវនាការដែរ។ មេធាវីការពារក្ដីសូមស្នើដោយគោរពថា អង្គជំនុំជម្រះសាលាដំបូងសូមពិចារណាឲ្យបានត្រឹមត្រូវចំពោះវិធាន៨៤(១) នៃវិធានផ្ទៃក្នុង ហើយមិនឯកភាពតាមការជម្រុញទៅលើការអនុវត្តបទប្បញ្ញត្តិនានានៃវិធានដែលអនុវត្តនៅតុលាការ ICTY ឡើយ។ ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបែបនេះជាការត្រឹមត្រូវ និងគ្មានការស្រពិចស្រពិលទេ។ ជាគោលការណ៍រួម មេធាវីការពារក្ដីមានសិទ្ធិក្នុងការសាកសួរដេញដោលទៅលើភស្តុតាងពីសាក្សីដាក់បន្ទុក ហើយ

---

[៣៩] សារណារបស់លោក អៀង សារី ប្រឆាំងនឹងការប្រើប្រាស់សម្ភារៈទាំងអស់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រមូល, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ E59។

[៤០] សំណុំរឿង០០១, អ.ជ.ស.ដ, សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង, ឯកសារលេខ E43/4, កថាខណ្ឌ១៣-១៦។

ប្រសិនបើសាក្សីនោះបានស្លាប់បាត់បង់ជីវិតទៅហើយ ភស្តុតាងនោះមិនអាចដាក់បន្ទុកបានទៀតទេ បើតាមបទដ្ឋាននៃការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌ជាអន្តរជាតិ។

### ៣.៨ ការទទួលយកប្រតិចារឹក

៤៩. មេធាវីការពារក្តីបដិសេធទៅនឹងការទទួលយកប្រតិចារឹកជាភស្តុតាង ដោយផ្អែកលើវិធាន៩២ នៃវិធានផ្ទៃក្នុង ដែលវិធាននេះគ្មានគោលបំណងយកមកប្រើប្រាស់សម្រាប់ការទទួលយកភស្តុតាងទេ។ យុទ្ធសាស្ត្ររបស់មេធាវីការពារក្តីក្នុងសំណុំរឿង ឌុច គឺមិនមែនជំទាស់ទៅនឹងភស្តុតាងភាគច្រើនដែលបានដាក់ដោយសហព្រះរាជអាជ្ញា ហេតុនេះ សាក្សីនានានៅក្នុងសវនាការលើសំណុំរឿងនោះ មិនត្រូវបានធ្វើការសួរតទល់ទេ ហើយភាពទុកចិត្តបាន និងភាពត្រឹមត្រូវរបស់សាក្សីទាំងនោះក៏មិនត្រូវបានពិនិត្យដែរ។

## V សេចក្តីសន្និដ្ឋាន

សម្រាប់សំអាងហេតុខាងលើ មេធាវីការពារក្តីស្នើសុំដោយគោរពចំពោះអង្គជំនុំជម្រះសាលាដំបូង៖

- ច្រានចោលទាំងស្រុងចំពោះសំណើរបស់ ក.ស.ព។
- អនុញ្ញាតឲ្យមេធាវីការពារក្តីមានសិទ្ធិសួរដេញដោលសាក្សីដាក់បន្ទុកនីមួយៗដែលផ្តល់សក្ខីកម្មក្នុងតុលាការ។
- ជាគោលការណ៍ អនុញ្ញាតឲ្យមេធាវីការពារក្តីមានសិទ្ធិសួរដេញដោលសាក្សីដែលបានផ្តល់ព័ត៌មានដាក់បន្ទុកអំពីជនជាប់ចោទ។
- មិនដាក់បញ្ចូលកំណត់ហេតុលាយលក្ខណ៍អក្សររបស់ ក.ស.ច.ស ដែលមិនពេញលេញ។
- ច្រានចោល "ចម្លើយសាក្សី" ទាំងអស់ ឬឯកសារភស្តុតាងដទៃទៀតដែលបានមកពី DC-Cam និង/ឬ ពីអង្គការ ឬបុគ្គលដទៃទៀតដែលមានលក្ខណៈស្រដៀងគ្នានេះ។
- បញ្ជាក់ថា ចម្លើយរបស់សាក្សីដែលបានស្លាប់បាត់បង់ជីវិតហើយ មិនអាចទទួលបានទេ។

- សម្រេចថា ប្រតិចារឹកនៃភស្តុតាងពីតុលាការផ្សេងទៀត មិនអាចទទួលយកបានទេ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | |